**សកម្មភាព** ៖ ល្បែង ត្រីនៅក្នុងសមុទ្រ

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

បំណិនចលកធំ (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំតូច និងសាច់ដុំធំ)។

**បុរេគណិត**

ទំហំ និងពណ៌ (ចំណាត់ក្រុម និងលំដាប់លំដោយ)

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីររបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។

បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

**(បុរេគណិត)** កុមារអាចចេះរៀបវត្ថុតាមលំដាប់ ទំហំ ប្រភេទ និងពណ៌។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង ៉តើអ្នកចង់ធ្វើការងារអ្វី? ៉

**រយៈពេល** ៖ ១០ នាទី

**ឧបករណ៍** ៖ ត្រូវមានកាតពណ៌(1-1, 1-2, 1-3)សម្រាប់ក្មេងៗទាំងអស់ ។

ជ្រើសរើសកន្លែងដែលមានទីធ្លាធំទូលាយសម្រាប់ធ្វើជាសមុទ្រ។

កន្លែងដែលជ្រើសរើសត្រូវមានខ្សែបន្ទាត់២សងខាង។

**ការរៀបចំ** ៖ អ៊ុតក្រដាសកាតពណ៌យ៉ាងហោចណាស់ ៦ពណ៌ផ្សេងគ្នា។

កាត់វាទៅជា ៨សន្លឹកតូចៗ និងអ៊ុតវាឱ្យបានស្អាត។

**សេចក្ដីណែនាំ៖**

1. ប្រាប់ក្មេងថាលេងល្បែង ត្រីក្នុងសមុទ្រ ។
2. បង្ហាញកាតពណ៌ទាំង ៦ពណ៌ដល់ក្មេងៗ។
3. និយាយពីពណ៌ទាំងនោះឱ្យលឿនៗ ក្មេងៗត្រូវនិយាយតាមដើម្បីឱ្យចងចាំបានល្អ។
4. ក្មេងៗត្រូវលាក់កាតពណ៌ ជៀសវាងកុំឱ្យគេផ្សេងបានឃើញ ។
5. ប្រាប់ឱ្យក្មេងទាំងអស់ឈរនៅពីក្រោយខ្សែបន្ទាត់។
6. ពន្យល់ពីច្បាប់ក្នុងការលេងល្បែងនេះ
    - ជ្រើសរើសក្មេង ១នាក់ ឬ ២នាក់ ធ្វើជាអ្នកនេសាទត្រី ។

- ក្មេងផ្សេងៗទៀតត្រូវឈរពីក្រោយបន្ទាត់មួយ និងចាប់ផ្តើមរត់កាត់សមុទ្រទៅកាន់បន្ទាត់មួយផ្សេងទៀត។
- ក្មេងៗមានកាតពណ៌ម្នាក់១ សន្លឹកខុសៗគ្នា ហើយត្រូវចាត់ទុកជាត្រីក្នុងសមុទ្រ។
- អ្នកនេសាទចាប់ផ្តើមស្រែកហៅពណ៌ណាមួយដែលគេស្រឡាញ់ឱ្យឮខ្លាំងៗ ។
- ក្មេងៗដែលជាត្រីទាំងអស់ត្រូវព្យាយាមរត់គេច និងអ្នកនេសាទត្រូវព្យាយាមចាប់ត្រីទាំងនោះ។
- អ្នកនេសាទត្រូវព្យាយាមចាប់ត្រីដែលមានកាតពណ៌ដូចដែលអ្នកនេសាទបានស្រែកហៅពណ៌។
- តែបើត្រីដែលត្រូវចាប់បានគ្មានកាតពណ៌ដែលគេស្រែកនោះទេ ត្រូវតែដោះលែងត្រីនោះវិញ។
- បើត្រីមានកាតពណ៌ដែលអ្នកនេសាទនោះស្រែកហៅត្រីនោះ ត្រូវនៅចំកណ្តាលជាមួយអ្នកនេសាទហើយនឹងត្រូវជួយចាប់ត្រីផ្សេងទៀត ។
- ត្រីត្រូវបានដោះលែងទៅវិញពួកគេអាចផ្លាស់ប្តូរកាតពណ៌របស់ពួកគេជាមួយត្រីផ្សេងទៀតបានដោយសប្បាយ ។
- ពេលដែលត្រីទាំងអស់បានរត់កាត់សមុទ្រ និងទៅដល់ខ្សែម្ខាងទៀតនោះអ្នកនេសាទត្រូវស្រែកពណ៌មួយផ្សេងទៀត និងបន្ទាប់មកធ្វើដូចដើម ។
- ធ្វើបែបហ្នឹងរហូតដល់នៅសល់ក្មេង ១ ឬ ២នាក់។ ហើយក្មេងទាំងនោះគឺនឹងក្លាយទៅជាអ្នកនេសាទត្រីម្តង និងចាប់ផ្តើមល្បែងម្តងទៀតបាន។

**ការប្រែប្រួលៈ**

ល្បែងនេះអាចលេងជាមួយ ឬប្រើកាតសត្វ ផ្លែឈើ បន្លែ និងថ្ងៃនៃសប្តាហ៍បាន។